# របៀបដាំ ថែរក្សា ការពារ និង ប្រមូលផល ដំណាំ ផ្តៅ



**ការបកប្រែពីឯកសារ** Rattan For Life

អង្គការសហគមន៍ព្រៃឈើអន្តរជាតិ
**Community Forestry International**

បណ្តាញអនុផលព្រៃឈើ
**Non-Timber Forest Products**

## ដំណាំផ្តៅ Rattan For Life

ការអនុវត្តផលលិតផលដំណាំផ្តៅ នៅស្រុក ដាន់យ៉ាក់ បេនវ៉ាក់ នៃខេត្តកាលីម៉ាន់តាន់ ប្រទេសឥណ្ឌូនេស៊ីៈ សៀវភៅព័ត៌មានក្បួនខ្នាត

សៀវភៅនេះជាច្បាប់កម្មសិទ្ធ របស់ប្រជាជននៅស្រុកដាន់យ៉ាក់ បេនវ៉ាក់ ដែលត្រូវបានប្រគល់អោយ SHK-Kalimantan Timur ជាមួយនឹងឯកសារប្រពៃណីយ៏ផ្សេងៗទៀត

ម្ចាស់កម្មសិទ្ធៈ SHK-Kalimantan Timur NTFP-Exchange Programme, ហើយនឹង Studio Driya Media-Bandung.

ការបោះពុម្ពផ្សាយនេះបានបង្កើតឡើងដោយ NTFP និងត្រូវបានអនុញ្ញាតិសំរាប់ការអប់រំទូទៅ។

ប្រសិនបើចង់បានសៀវភៅនេះ សូមទាក់ទងៈ

អង្គការសហគមន៍ព្រៃឈើអន្តជាតិនៅកម្ពុជា
ផ្ទះលេខ ៨១ បេ ផ្លូវលេខ ៥៧ កែងផ្លូវលេខ ៣៩៨. សង្កាត់បឹងកេងកង១
ខ័ណ្ឌចំកាមន ក្រុងភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (៨៥៥ ២៣ ២២០ ៧១៤
ទូរសារលេខ : (៨៥៥ ២៣ ២២១ ៦៣៤
អ៊ីម៉ែល : cfioffice@cfi-cambodia.org.kh

ការបោះពុម្ពផ្សាយលើកទី១ ២០០១
និពន្ធដោយ : ពីពីន អិន សាឌីគីន និង ហ្វីដីលីស នីយ៉ុងការ
គូរូបភាពដោយ : អាយឆឺវ៉ាន់ សេទីយ៉ាវ៉ាន់

# របៀបដាំ ថែរក្សា ការពារ និង ប្រមូលផលដំណាំ

# ផ្ដៅ

ការបកប្រែពីឯកសារ Rattan For Life

អង្គការសហគមន៍ព្រៃឈើអន្តរជាតិ
Community Forestry International

បណ្ដាញអនុផលព្រៃឈើ
Non-Timber Forest Products

# មាតិការ


| | ទំព័រ |
|---|---|
| សេចក្តីផ្តើម | ៣ |
| ១. លក្ខណៈពិសេសនៃការគ្រប់គ្រងផ្តៅ | ៤ |
| ប្រភេទផ្តៅ | ៤ |
| លក្ខខណ្ឌលូតលាស់ | ៥ |
| ការបង្កើតចំការផ្តៅ | ៦ |
| ២. ដំណាក់កាលក្នុងការដាំផ្តៅ | ៦ |
| ការរៀបចំដី | ៦ |
| ការរៀបចំគ្រាប់ និងកូនផ្តៅ | ៨ |
| ការទទួលយកគ្រាប់ពូជ | ៩ |
| ការដាំកូនផ្តៅ | ១០ |
| ការដាំដុះ | ១១ |
| ការថែរក្សាផ្តៅ | ១១ |
| ៣. ការដកហូតផ្តៅ | ១១ |
| ៤. ប្រព្រឹត្តកម្មបន្ទាប់ពីការប្រមូលផល | ១៣ |
| ការលក់ដូរ | ១៤ |
| តារាងប្រភេទ និងលក្ខណៈរបស់ផ្តៅ | ១៧ |
| ឯកសារយោង | ១៨ |




# សេចក្តីផ្តើម

ផ្តៅភាគច្រើនជាពពួករុក្ខជាតិវល្លិ តោងដែលដុះក្នុងព្រៃធម្មជាតិក្នុងប្រទេសកម្ពុជាហើយត្រូវបានប្រជាជនជនបទប្រើប្រាស់ក្នុងគោលបំណងជាច្រើន ។ គ្រឿងសង្ហារឹមធ្វើពីផ្តៅគឺជាផលិតផលពេញនិយមរបស់ប្រជាជនទាំងនៅក្នុងស្រុក និងនៅក្រៅប្រទេស ។

នៅតំបន់មួយចំនួននៃប្រទេសឡាវ និងថៃ ប្រជាជនយកបណ្តូលផ្តៅធ្វើជាអាហារ ។ ដើមផ្តៅត្រូវបានគេយកមកផលិតជាគ្រឿងសង្ហារឹមច្រើនប្រភេទ ដូចជា តុ ទូ កៅ អី ។ល ។ ប្រភេទផ្តៅធំៗដែលមាននៅប្រទេសកម្ពុជារួមមាន ដំបង ស្វាំង ព្រះផ្តៅ សោមនិងប្រភេទផ្តៅតូចៗជាច្រើនទៀតដែលទទួលបានការពេញនិយមដូចគ្នា ។ ប្រភពផ្គត់ផ្គង់ ផ្តៅសំខាន់ៗរួមមាន ពេជ្រនិល ខេត្តក្រចេះ បាត់ដំបង និងនៅពេជ្រនិល ។

ដោយយល់ឃើញពីសារៈសំខាន់របស់ផ្តៅច្រើនយ៉ាងបែបនេះ និងដោយមានការស្នើរសុំឱ្យមានការបកប្រែឯកសារនេះ ទើបអង្គការសហគមន៍ព្រៃឈើអន្តរជាតិ (CFI ស្វែងរកឯកសារទាក់ទងនឹងផ្តៅមកបកប្រែជាភាសាខ្មែរ ដើម្បីឱ្យអ្នកធ្វើការងារទាក់ទងនឹងរុក្ខជាតិនេះយល់ដឹងពីរបៀបដាំ ថែរក្សា ការពារ និងប្រមូលផល ដើម្បីធ្វើឱ្យមានផ្តៅប្រើប្រាស់យូរអង្វែងទៅថ្ងៃក្រោយ ។ តែបច្ចេកទេសដែលមាននៅ ក្នុងសៀវភៅនេះមិនដូចគ្នាទៅនឹងតំបន់ផ្សេងៗឡើយ ។ នៅប្រទេសកម្ពុជា ការថែរក្សា ការគ្រប់គ្រង ការដាំ និងការដកហូត ប្រហែលជាមានភាពខុសគ្នាខ្លះៗ អាស្រ័យលើអាកាសធាតុ ស្ថានភាពដី ឬប្រពៃណីទំនៀមទំលាប់ ។

ព័ត៌មាននិងបច្ចេកទេសដែលមានក្នុងសៀវភៅនេះ គឺ ជាការបកប្រែមកពីសៀវភៅមួយដែលមានចំណងជើងថា ឬ **ផ្តៅសំរាប់ជីវិត រស់នៅ** (RATTAN FOR LIFE) ដែលរៀបចំ និងបោះពុម្ពដោយ អង្គការ NTFP , SHK KALTIM និង DRIYAM នៅប្រទេសឥណ្ឌូនេស៊ី ។

## ១. លក្ខណៈពិសេសនៃការគ្រប់គ្រងផ្តៅ

### ■ ប្រភេទផ្តៅ

នៅក្នុងតំបន់ Dayak Benuaq ដែលនៅជិតនឹងទន្លេ Lawa ( នៅក្នុងតំបន់ Kutai ខាងលិច នៅភាគខាងកើតកោះ Kalimantan មានផ្តៅដែលគេស្គាល់ប្រហែល ៣០ ប្រភេទ ។ ប្រភេទផ្តៅជាច្រើនមានបង្ហាញក្នុង តារាង ទី ១ ។




ផ្តៅគ្រប់ប្រភេទទាំងអស់មានឫសធំ និងសរសៃឆ្មារៗ(ឫសរយាង និងមានដើម និងឫស ផ្លែជាច្រើន ។ មានប្រភេទផ្តៅដុះជាគុម្ព និងវាលើដី ។ ប្រភេទផ្តៅដែល ត្រូវបានដាំ និងប្រើប្រាស់ញឹកញាប់ជាងគេសំរាប់ ជីវភាពប្រចាំថ្ងៃរបស់ប្រជាជនក្នុងតំបន់ Dayak Benuaq នោះគឺពូជ Sega ។ ពូជផ្តៅ Sega



មានលក្ខណៈរឹង និងងាយកែច្នៃបើប្រៀបធៀបជាមួយនឹងប្រភេទផ្តៅផ្សេងៗ ទៀត។ ផ្តៅប្រភេទ Sega ក៏អាចលក់ដូរបានច្រើនដែរ ដោយសារតែវាមានទីផ្សាររួចជាស្រេចហើយ ។ ផ្តៅប្រភេទ Sega ដែលមានអង្កត់ផ្ចិតតូចជាទូទៅត្រូវបានប្រើប្រាស់ដោយឧស្សាហកម្មផលិតព្រំ និងឈើគ្រឿងសង្ហារឹម ។ ផ្តៅប្រភេទ Sega មួយដើមអាចមានប្រវែងជាង ៣០ ម៉ែត្រ ដោយមានអង្កត់ផ្ចិតពី ១ សម ទៅ ២ សម និងមានចន្លោះប្រវែង ៥០ សម ។

### ■ លក្ខខណ្ឌលូតលាស់

ជាទូទៅ ប្រសិនបើប្រភេទផ្តៅមួយអាចលូតលាស់បាននៅកន្លែងមួយ នោះប្រភេទផ្តៅផ្សេងទៀតក៏អាចលូតលាស់នៅកន្លែងនោះបានដែរ ។



ផ្តៅអាចដុះបានល្អនៅតំបន់សើម ដែលមានទឹកគ្រប់គ្រាន់ពីព្រោះផ្តៅ ជារុក្ខជាតិដែលស្រូបទឹក ។ ដោយ ហេតុដូច្នេះហើយ បានជាផ្តៅមាន នៅតាមដងទន្លេ និងតំបន់ភ្នំ ។ ផ្តៅ ដែលដុះក្បែរដៃទន្លេតូចៗ នៅតំបន់ ភ្នំមានគុណភាពខ្ពស់ ។ ប្រភេទផ្តៅជាច្រើន ដូចជា Jahap, Jepung និង Pelas អាចដាំបាននៅតំបន់ដែលមានទឹកដក់ដោយសារទឹកជំនន់នៅរដូវវស្សា ។ ផ្តៅប្រភេទ

Segaអាចដាំបាននៅតាមដងទន្លេ និងតំបន់ភ្នំដែលមានដីឥដ្ឋ និងមានសំណើមខ្ពស់ មានភ្លៀងធ្លាក់ច្រើន និងកំដៅគ្រប់គ្រាន់ ។

### ■ ការបង្កើតចំការផ្តៅ

ដោយមានការប្រើបច្ចេកទេសគ្រប់គ្រងសមស្រប ចំការផ្តៅដែលដាំដោយប្រជាជនក្នុងតំបន់ Dayak Benuaq អាចមានអាយុរាប់ទសវត្សរ៍ ។ គេប្រមូលផលផ្តៅតែមួយផ្នែកប៉ុណ្ណោះនៅក្នុងឆ្នាំប្រមូលផលនីមួយៗ ដើម្បីធានានូវការផ្គត់ផ្គង់គ្រប់គ្រាន់ទៅថ្ងៃក្រោយ ។ វិធីសាស្ត្រប្រមូលផលនេះការពារផ្តៅឱ្យមាននៅតាមទីជម្រាល និងតាមជួរភ្នំ ហើយតាមរយៈនេះវាអាចការពារការហូរច្រោះដីនៅជុំវិញទន្លេ និងនៅតាមទីជម្រាលភ្នំផងដែរ ។

## ២. ដំណាក់កាលក្នុងការដាំផ្តៅ

### ■ ការរៀបចំដី

ស្របទៅនឹងប្រព័ន្ធវិលជុំដែលគេប្រើក្នុងការដាំដុះ គេធ្វើចំការផ្តៅក្នុងគោលបំណងធ្វើឱ្យដីមានជីជាតិឡើងវិញ( ធ្វើដីឱ្យនៅទំនេរ ។ ជាទូទៅ

1 ចំការផ្តៅ នៅព្រៃរបោះ(Simpukng Munan ដែលប្រជាជន Dayak Benuaq ដាំជាមួយនឹង រុក្ខជាតិហូបផ្លែពួកប្រភេទអាយុវែង និងផ្តៅ ។ ទោះបីជាយ៉ាងណា ក្នុងអត្ថបទផ្សេងៗទៀត អ្នកអាចឃើញថាប្រពន្ធ័នេះ គេហៅថា សួនផ្តៅ ប៉ុន្តែ អ្នករៀបរៀងសៀវភៅជំនួយស្មារតីនេះ គិតថាពាក្យចំការផ្តៅ មានន័យប្រហាក់ប្រហែលគ្នាទៅ នឹងប្រពន្ធ័នេះ ។



នៅពេលដែលគេរៀបចំដីសំរាប់ចំការផ្តៅ ប្រជាជននៅក្នុងតំបន់ Dayak Benuaq យកដីនេះធ្វើស្រែ ឬ ដាំដំណាំផ្សេងៗ រយៈពេលបីឆ្នាំដំបូងសិន ។



នៅពេលរានដីសំរាប់ដាំដុះ គេរៀចំដីដោយដុតរុក្ខជាតិដែលបានរំលំជាមុនសិន ។ វិធីដុតរបស់ពួកគេត្រូវតែប្រុងប្រយត្ន័បំផុត ។ គេកាប់ដើមឈើ និងមែកឈើនៅលើដីនេះ ហើយទុកវាចោល ២ សប្តាហ៏រហូតទាល់តែវាស្ងួត ។ បន្ទាប់មក ប្រជាជនក្នុងតំបន់ Dayak Benuaq ធ្វើផ្លូវភ្លើង ។ ដើម្បីធ្វើផ្លូវភ្លើងបាន គេត្រូវសំអាតមែកឈើ និងស្លឹកស្ងួតៗ ដែលងាយឆេះពីតំបន់ក្បែរៗនោះចំងាយពី ១ម ទៅ ២ម ។ បន្ទាប់មកគេធ្វើព្រំប្រទល់ជុំវិញទីវាលនោះ។ ព្រំប្រទល់នេះ មានទទឹងប្រហែល ១ ម ហើយដកយកស្លឹកឈើ និងមែកឈើដែលងាយឆេះចេញ ។ នៅពេលគេធ្វើការដុត ពេលនោះព្រំប្រទល់នេះមិនឆេះទេ ។ វិធីនេះធានាថា ភ្លើងនឹងមិនឆេះរាលដាលដល់តំបន់ក្បែរ ខាងនោះទេ ។

នៅតែមានប្រជាជនចាប់ផ្តើមធ្វើចំការផ្តៅក្នុងកសិដ្ឋានរបស់ពួកគេ ដោយមិនមានរៀបចំដីជាមុនផងដែរ ។ គេអាចហៅការធ្វើបែបនេះថាជាការដាំបង្កើនជីជាតិដីនៅក្នុងព្រៃផងដែរ ។

## ■ ការរៀបចំគ្រាប់ និងកូនផ្តៅ *(រោងសំណាប)*

គេអាចបណ្តុះផ្តៅដោយគ្រាប់ពូជ និងកូនផ្តៅ ។ ប្រជាជនក្នុងតំបន់ Dayak Benuaq ភាគច្រើននិយមដាំផ្តៅពីគ្រាប់ពូជ ។ ការដាំដុះបែបនេះគេគិតថាមានប្រយោជន៍ច្រើន ពីព្រោះវាមិនត្រូវការការងារបន្ថែមច្រើន ។

## ■ ការទទួលយកគ្រាប់ពូជ

ជាទូទៅ គេយកគ្រាប់ពូជពីផ្លែផ្តៅដែលមានអាយុគ្រប់ ៦ ខែ ដែលគេចាត់ទុកថាពេញលក្ខណៈ ។ គេត្រូវបកសំបកផ្លែផ្តៅ ហើយទុកដាក់វាក្នុង កន្ត្រក ឬ ជៀល ។




បន្ទាប់មកគេយកគ្រាប់ពូជនេះទៅត្រាំទឹកដើម្បីអោយសាច់វាឡើងទន់ ហើយបន្ទាប់មកគេយកគ្រាប់ពូជចេញ និងដាក់ហាលថ្ងៃឱ្យស្ងួតទឹក ។ គេអាចដាំគ្រាប់ស្ងួតនេះភ្លាមឬ ទុកសិនក៏បាន ។



## ■ ការដាំកូនផ្តៅ



គេអាចយកកូនផ្តៅដោយផ្ទាល់ពីចំការផ្តៅ ឬ ពីព្រៃ ។ គេដកកូនផ្តៅ ដោយប្រុងប្រយ័ត្នពីដីដោយមិនឱ្យដាច់ឫសកែវវា ។ ប្រជាជនក្នុងតំបន់ DayaK Benuaq មានដំណើរការជាពិសេសក្នុងការដាំកូនផ្តៅ ដោយយកខ្សែរផ្តៅចងកូនផ្តៅជាច្រើនយ៉ាងស្រាលៗ ដោយមិនរិតតឹងភ្ជាប់ទៅនឹងបង្គោលឈើ ។ បន្ទាប់មក គេដាំកូនផ្តៅមួយបាច់នេះទៅក្នុងដីដែលនៅជិតប្រភពទឹក ។ ឫសវាត្រូវតែលិចទៅក្នុងទឹក ។ បន្ទាប់ពីមួយរយៈពេលខ្លីមក ស្លឹកទាំងអស់នឹងស្វិតហើយជ្រុះ បន្ទាប់ពីនោះស្លឹកថ្មីនឹងដុះឡើងមកវិញ ។ គេអាចដាំកូនផ្តៅក្នុងដីដែលរៀបចំសំរាប់វា បន្ទាប់ពីស្លឹកថ្មី ២ ឬ ៣ ដុះចេញមក ។

តាមវិធីនេះ កូនផ្តៅនឹងអាចមានជីវិតរស់បានតាមរយៈការដាំដុះ បើប្រៀបធៀបទៅនឹងគ្រាប់ពូជដែលមិនមានប្រព្រឹត្តិកម្មជាពិសេសបែបនេះ ។

## ■ ការដាំដុះ

គេដាំផ្តៅនៅរដូវវស្សា ។ ប្រសិនបើចំការផ្តៅត្រូវបានគេប្រើប្រាស់ សំរាប់ធ្វើស្រែពីមុនមក ការដាំគ្រាប់ពូជផ្តៅអាចធ្វើទៅបានក្នុងរយៈពេលពី ១ ទៅ ២ ថ្ងៃ មុនពេលធ្វើការដុតដី បន្ទាប់ពីការដុតដីនៅពេលដែលស្រូវកំពុងលូតលាស់ ឬបន្ទាប់ពីការប្រមូលផលស្រូវ ។ គេអាចដាំកូនផ្តៅបានបន្ទាប់ពី គេដុតដី ហើយនៅពេលពន្លកស្រូវកំពុងលូតលាស់ក៏បាន ឬបន្ទាប់ពីប្រមូលផល ស្រូវ ព្រោះប្រសិនបើគេដាំកូនផ្តៅមុនពេលដុត ពេលនោះកូនផ្តៅនឹងត្រូវឆេះខូចអស់ ។

ដើម្បីបណ្តុះផ្តៅ ប្រជាជនក្នុងតំបន់ Dayak Benuaq ដាំវាចោះៗនៅជុំវិញដើមឈើ ឬគល់ឈើ ។ ជាទូទៅ គេដាំជាបីរណ្តៅជុំវិញដើមឈើឬគល់ឈើនោះ ។ ប្រសិនបើគេដាំគ្រាប់ពូជនោះមុនពេលដុតដី គេត្រូវយកស្លឹកឈើ និងមែកឈើចេញពីជុំវិញគល់ឈើ ក្រោយពីធ្វើការដាំហើយ ។ បន្ទាប់មកគេ អាចធ្វើការដុតដីនេះបាន ។

តាមវិធីបែបនេះ គ្រាប់ពូជនឹងមិនអាចឆេះបានឡើយ ពីព្រោះវាត្រូវបានដាំទៅក្នុងដីរួចស្រេចហើយ ។ វិធីដុតដីនេះ អាចធ្វើឱ្យផ្តៅលូតលាស់លឿនពីព្រោះកំទេចស្លឹកឈើ និងមែកឈើដែលបានដុតនោះអាចបន្ថែមសាធាតុមានប្រយោជន៍ទៅឱ្យដី ។ ការដាំផ្តៅនៅលើដី ដែលមិនបានប្រើសំរាប់ធ្វើស្រែពីមុនមកក៏អាចធ្វើទៅបានផងដែរ ។



## ■ ការថែទាំផ្តៅ

ជាធម្មតា គេអាចថែទាំផ្តៅប្រចាំថ្ងៃដោយសំអាតស្មៅ ឬស និងកាប់ដើមឈើតូចៗនៅជុំវិញគុម្ពផ្តៅ ។ តែដើមឈើទំហំមធ្យម និងធំៗ ដែលដុះនៅជុំវិញគុម្ពផ្តៅមិនគួរកាប់រំលំវាទេ ព្រោះវានាំឱ្យប៉ះពាល់ដល់



ប្រភេទផ្តៅដែលវានឹងតោង ។ វិធីធម្មតាក្នុងការសំអាតដើមឈើ គឺជៀរសំបកខាងក្រៅជុំវិញដើមឈើ ប្រវែងប្រហែលមួយហាត់ដៃ ។

## ៣. ការដកហូតផ្តៅ

ការព្រួយបារម្ភណ៏របស់រដ្ឋាភិបាលដែលថា ការធ្វើអាជីវកម្មផ្តៅហួសប្រមាណ នឹងអាចធ្វើឱ្យហិនហោចដល់ខ្លួនគឺមិនមានលក្ខណៈសមហេតុផលដល់ប្រជាជនក្នុងតំបន់ Dayak Benuaq ទេ ពីព្រោះពួកគេប្រើប្រាស់ចំណេះដឹងជា ប្រពៃណីក្នុងការ ប្រមូលផលផ្តៅទាំងនេះ ។ ពួកគេធ្វើការថែរក្សា ការពារដំណាំផ្តៅ ព្រោះពួកគេចាត់ទុក វាថាមានផលប្រយោជន៏ដល់ការអភិរក្ស បរិស្ថាន ។

ពួកគេដឹងពីរបៀបប្រមូលផលផ្តៅជាលក្ខណៈជម្រើសដោយយកចិត្ត ទុកដាក់ចំពោះការការពារដើមឈើដែលមានផ្តៅដុះលូតលាស់ជាមួយ និងថែរក្សា ការពារផ្តៅនោះផង ។ ការប្រើប្រាស់បច្ចេកទេសរបស់ពួកគេបែបនេះ គេមិន អាច ធ្វើឱ្យបាត់បង់ផ្តៅទាំងស្រុងនោះទេ តែគេអាចទុកផ្នែកខ្លះនៅសល់ ។

ដើមឈើដែលប្រើសំរាប់បណ្តុះផ្តៅនោះក៏មិនត្រូវកាប់ដែរ លើកលែង តែដើមឈើនេះចាស់ពេក។ វិធីសាស្ត្រប្រមូលផលផ្តៅរបស់ពួកគេធ្វើឡើង ដោយទាញផ្តៅចេញពីដើមឈើដែលវាតោង ហើយឆ្កាបន្លាខាងក្រៅសំបក ចេញដោយកាំបិត ។ ប្រសិនបើគេមិនអាចដកផ្តៅទាញចេញពីដើមឈើទេ នោះ គេនៅមានវិធីសាស្ត្រពីរយ៉ាងទៀតក្នុងប្រមូលផលវា ។ វិធីសាស្ត្រទី១ ត្រូវឱ្យមនុស្សម្នាក់ឡើងដើមឈើ ហើយកាប់ផ្តាច់ស្លឹកបន្លាដែលតោងជាប់ដើមឈើចេញ ឬប្រសិនបើដើម ឈើនោះចាស់ហើយ គេអាចកាប់រលំដើមឈើនោះដោយពូថៅតែម្តង ។ បន្ទាប់ពីនោះ គេអាចកាប់ផ្តៅប្រហែលពី ២ម ពីចុងវា ហើយកាប់ប្រហែល ១ម ពី គល់វានៅនឹងដី ។

ជាធម្មតា បន្ទាប់ពីការប្រមូលផលផ្តៅមក គេត្រូវប្រមូលវាដាក់លើគំនរដែលមានកំណាត់ឈើជាច្រើន ដែលរៀបចំជាទ្រនាប់សំរាប់ផ្តៅ ។ គេកាប់ផ្តៅទៅតាមទំហំដែលចង់បាន ។ជាធម្មតា គេកាប់ផ្តៅប្រវែងប្រហែល៦ម បន្ទាប់មកបត់វាជាពីរដើម្បីងាយស្រួលដឹកជញ្ជូន។



## ៤. ប្រព្រឹត្តកម្មបន្ទាប់ពីការប្រមូលផល

ប្រសិនបើផ្តៅនោះនឹងយកទៅលក់នៅទីផ្សារ គេត្រូវធ្វើប្រព្រឹត្តិកម្មវាជាមុនសិន។ ប្រព្រឹត្តកម្មនោះអាចរួមបញ្ចូលទាំងការសំអាតផ្តៅ ការឆ្អើរ ការសម្ងួត និងការចងវា ។

ជាធម្មតា ប្រជាជនក្នុងតំបន់ Dayak Benuaq សំអាតផ្តៅដោយ ប្រើប្រាស់ខ្សែលួស ដើម្បីបកសំបកខាងក្រៅ និងភាពក្រខ្វក់ ។ ក្រោយមក គេគរផ្តៅលើរានឈើមួយដែលមិនធំពេកទេ ។ បន្ទាប់ពីនោះ គេគ្របគំនរផ្តៅ នោះដោយកៅស៊ូប៉ាតង់ដែលមិនជ្រាបទឹក ហើយគេឆ្អើរផ្តៅនោះពី ២ ទៅ ៣ ថ្ងៃ ដោយស្ពាន់ធ័រ ។

មិនមានអនុបាតស្ពាន់ធ័រកំណត់ច្បាស់លាស់សំរាប់ចំនួនផ្តៅដែលត្រូវឆ្អើរនោះទេ ។ តែកសិករមួយចំនួនឱ្យប្រើស្ពាន់ធ័រ ១ គីឡូក្រាម សំរាប់ឆ្អើផ្តៅ ២ ទៅ ៣ តោន ។ បន្ទាប់ពីឆ្អើរហើយ គេយកផ្តៅទៅហាលថ្ងៃនៅវាលចំហរលើទ្រនាប់ឈើមូលៗ ឬបន្ទះក្តារាបស្មើក្នុងរយៈពី ២ ទៅ ៣ ថ្ងៃ ។ បន្ទាប់មក គេចងផ្តៅ ហើយរៀបចំយកទៅលក់ ឬស្តុក ទុកបានហើយ ។



## ■ ការលក់ដូរ

ជាធម្មតា ការលក់ដូរផ្តៅមិនសូវមានលក្ខណៈខុសគ្នាទេបើយោងតាមការពន្យល់ពីការអ្នកលក់គ្រឿងសង្ហារឹមផ្តៅនៅទីក្រុងភ្នំពេញ ។

ប្រជាជនក្នុងតំបន់ Dayak Benuaq លក់ផ្តៅមិនទាន់កែ ឆ្នៃទៅឱ្យឈ្មួញប្រមូលទិញផ្តៅនៅក្នុងភូមិ ឬនៅក្បែរទីក្រុងដែលនៅជិតបំផុត ។ បន្ទាប់មកឈ្មួញនោះលក់ផ្តៅបន្តទៅឱ្យឈ្មួញនៅក្នុងទីក្រុង ឈ្មួញនោះ លក់បន្តទៅឱ្យឈ្មួញនៅក្រៅតំបន់ Kalimantan ខាងកើត ឬ ទៅឱ្យឧស្សាហកម្មផលិតគ្រឿងសង្ហារឹមដែលប្រមូលផ្តុំគ្នានៅលើកោះជ្វា ។ មានអ្នកលក់ផ្តៅ ក្នុងទំរង់ជាសិប្បកម្ម ផងដែរនៅតាមផ្សារក្នុងតំបន់ ឬទៅឱ្យឈ្មួញកណ្តាល ។ ឈ្មួញកណ្តាលនោះ ដឹកជញ្ជូន កន្រ្តកកន្ទេល និងអ្វីដែលជាផលិតផលផ្តៅនោះ ទៅកាន់ក្រុង បាលី និងទីកន្លែងផ្សេងៗទៀត ។ ឧស្សាហកម្មសិប្បកម្មខ្នាតតូចនៅស្រុក Kalimantan ខាងកើត ប្រើប្រាស់ដើមពីផ្តៅច្រើនប្រភេទក្នុងការរចនាម៉ូដតាមតំបន់ខុសៗគ្នា ។

តាមការសាកសួរអ្នកលក់គ្រឿងសង្ហារឹមផ្តៅនៅទីក្រុងភ្នំពេញបានឱ្យដឹងថាផ្តៅភាគច្រើននាំមកពីតំបន់ពេជ្រនិល ខេត្តក្រចេះ និងបាត់ដំបង ហើយយកមកលក់ឱ្យសិប្បកម្មផលិតនៅក្នុងទីក្រុងដើម្បីផលិតជាគ្រឿងសង្ហារឹមផ្តៅ និងលក់បន្តទៅឱ្យហាងលក់គ្រឿងសង្ហារឹម ។ តាមព័ត៌មានដដែលបានឱ្យដឹងថាការផ្គត់ផ្គង់ផ្តៅនាពេលនេះមានការថយចុះយ៉ាងខ្លាំងដោយសារតែការដកហូតមិនបានត្រឹមត្រូវ និងគ្មានការថែរក្សាដាំដុះឡើងវិញ ។ ប្រភេទផ្តៅសំខាន់ៗ ដែលមាននៅប្រទេសកម្ពុជារួមមាន ផ្តៅដំបង ផ្តៅស្វាំង និងព្រះផ្តៅ ។ ក្រៅពីនេះនៅមានប្រភេទជាច្រើនផ្សេងទៀតតែមិនមានប្រភពព័ត៌មានច្បាស់ លាស់ ។



បើយោងតាមលោក Tom D.Evans ដែលបានធ្វើការស្រាវជ្រាវអំពីផ្តៅនៅក្នុងតំបន់អាស៊ីអគ្នេយ៍សំរាប់ថ្នាក់បណ្ឌិតរបស់គាត់បានបញ្ជាក់ថានៅប្រទេសកម្ពុជា គេឃើញមានប្រភេទផ្តៅទូទៅចំនួន ៥ រួមមាន ៖ តំបង *(Calamus rudentum)* ព្រះផ្តៅ (Calamus palustris) ស្វាំង (Calamus tetradactylus) ផ្តៅ (*Korthalsia laciniosa*) រំពាក់ (*Calamus Palustris*) ។ ព័ត៌មានលម្អិតអំពីប្រភេទនីមួយៗ សូមអាន សៀវភៅ *A Field Guide to the Rattans of Lao PDR* ។ តែត្រូវកត់សំគាល់ថា ឈ្មោះផ្តៅតាមតំបន់ជាទូទៅ មិនមានលក្ខណៈប្រាកដច្បាស់ទេសំរាប់ការធ្វើអត្តសញ្ញាណកម្ម ។



គ្រឿងសង្ហារឹមផ្តៅដែលផលិតនៅភ្នំពេញគឺភាគច្រើនផលិតសំរាប់លក់ក្នុងប្រទេសប៉ុណ្ណោះ ។ រូបភាពខាងក្រោមនេះគឺជាគ្រឿងសង្ហារឹមដែលផលិតពី ផ្តៅនៅក្នុងប្រទេសកម្ពុជា ៖







**តារាងអំពីប្រភេទ និងលក្ខណៈរបស់ផ្តៅ**

| ប្រភេទផ្តៅ | ស្លឹក | មែក/ទង | ពន្លក | បន្លា | ផ្លែ |
|---|---|---|---|---|---|
| Sega *(Calamus casesius)* | ផ្ទៃខាងលើពណ៌បៃតង និងរាងស និងមានរាងដូចទូកក្រឡាប់ | រាងជាដង្កុំ មានពណ៌បៃតង មានទំហំប្រហែលមេដៃ | Cirrus ដៃតោង ខាងចុងស្លឹក | ពណ៌បៃតង មិនមានលំដាប់ទៀងទាត់ | ពណ៌បៃតងខ្ចី បៃតងចាស់ ស |
| Jepuk *(Jepung bawon)* | មានរាងដូចទូកក្រឡាប់ មានកន្ទុយនៅខាងចុង | រាងជាដង្កុំ | Cirrus | តិច ធំ ពណ៌ត្នោត | - |
| Peles *(C. pinicillatus)* | មានរាងដូចទូកក្រឡាប់ តូច និងស្តើង ផ្ទៃរាងគគ្រើម | រាងជាដង្កុំ | Cirrus | តូច ញឹក | - |
| Boyukng (C. continues) | មានរាងដូចទូកក្រឡាប់ ចុងពណ៌បៃតង ពណ៌ក្រហមគ្រើមនៅម្ខាងទៀតនៃស្លឹក | រាងជាដង្កុំ មានពណ៌បៃតងខ្ចី | Cirrus | ញឹក | មានក្លិនឈ្ងុយ |
| Ngono *(C. manna)* | មានរាងដូចទូកក្រឡាប់ ចុងអាចបត់បែនបាន | ទោល មានទំហំស្មើនឹងកដៃ | Cirrus | ខ្មៅ តំរៀបជាជួរ ញឹក | ត្នោតចាស់ |
| Tuu *(C. scipinous)* | មានរាងដូចទូកក្រឡាប់ ពណ៌បៃតងព្រឿងៗ | រាងជាដង្កុំ ( មានពី ២-៦ ទង | Cirrus | រាងចតុកោណ ពណ៌លឿង | - |
| Tuu *(C. scipinous)* | មានរាងដូចទូកក្រឡាប់ ពណ៌បៃតងព្រឿងៗ | រាងជាដង្កុំ ( មានពី ២-៦ ទង | Cirrus | រាងចតុកោណ ពណ៌លឿង | - |
| Kotoq *(Daemonorops angqustifolia)* | មានរាងដូចស្លឹកដូង ចុងពណ៌ក្រហមចាស់ | រាងជាដង្កុំ | Cirrus | ស្រួច និងញឹក ពណ៌ត្នោតចាស់ | ពណ៌បៃតងចាស់ |
| Lalutn *(Korthalsia rigida)* | រាងដូចខ្លែង មានលក្ខណៈគ្រើមៗ និងពណ៌ត្នោត | រាងជាដង្កុំ ( មាន ៥-៤០ ទង | Cirrus | តូច | ពណ៌ស្រដែងត្នោត |

## ឯកសារយោង

Cahayat, A. (2001). “Improving The Rattan Resources Management and Trading System in Kalimantan.”

SHK-Kaltim. (2001) Draft Rattan Masterplan. Samarinda.

Mustikasari, R. (2001). Kompilasi Data Ekspor Rotan Dari BPS Seja Tahun 1970-1999, CIFOR.

Roedy Haryo Widjono AMZ, Masyarakat Dayak Menatap, Hari Esok, Grasindo, Jakarta, 1988.

Tom D. Evans (2001), Khamphone Sengdala, Oulathong V. Viengkham and Banxa.

Thammavong “A Field Guide to the Rattans of Lao PDR” (covers all 51 species

known from Lao PDR and nearby area).



**បោះពុម្ពដោយ**

**អង្គការសហគមន៍ព្រៃឈើអន្តរជាតិ (CFI)**

**សំរាប់ព័ត៌មានបន្ថែមអំពីអង្គការសហគមន៍ព្រៃឈើអន្តជាតិ សូមទាក់ទង:**

អង្គការសហគមន៍ព្រៃឈើអន្តជាតិនៅកម្ពុជា
ផ្ទះលេខ ៨១ បេ ផ្លូវលេខ ៥៧ កែងផ្លូវលេខ ៣៩៨. សង្កាត់បឹងកេងកង១
ខ័ណ្ឌចំការមន ក្រុងភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (៨៥៥ ២៣ ២២០ ៧១៤
ទូរសារលេខ : (៨៥៥ ២៣ ២២១ ៦៣៤
អ៊ីម៉ែល : cfioffice@cfi-cambodia.org.kh

**For further information about CFI, please contact:**

Community Forestry International
# 81b, Street 57, (Corner of St. 398), Sangkat Boeung Keng Kong 1, Khan Charmkar Morn, Phnom Penh, Cambodia
Tel: (855 23) 220 714
Fax: (855 23) 221 634
Email: cfioffice@cfi -cambodia.org.kh

**ឧបត្ថម្ភការបោះពុម្ពដោយ**

USAID FROM THE AMERICAN PEOPLE

MacArthur

This translation has been developed as an output of Community Forestry International’s Cambodia project. The project has been generously funded by the United States Agency for International Development and the John D. & Catherine T. MacArthur Foundation. The observations and opinions expressed in this publication are those of the authors and do not necessarily reflect any opinion whatever of these donors.